**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩៩. អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ធនាគារអភិវឌ្ឍន៍ជនបទ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើឱ្យច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០០៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ធនាគារអភិវឌ្ឍន៍ជនបទ ដែលសរសេរជាអក្សរកាត់ថា "**ធ.អ.ជ.**" និងសរសេរជាភាសាអង់គ្លេសថា "Rural Development Bank" ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ត្រូវបានកែសម្រួល តាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

**ធ.អ.ជ.** ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាគ្រឹះស្ថានធនាគារ និងមានស្វ័យភាពបរិបូរណ៍ក្នុងការដឹកនាំនិងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។

**ធ.អ.ជ.** មានគោលដៅផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដល់វិស័យកសិកម្ម ដើម្បីចូលរួមចំណែកអភិវឌ្ឍវិស័យកសិកម្មនិងសេដ្ឋកិច្ចជនបទ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តរបៀបវារៈគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

**ធ.អ.ជ.** មានភារកិច្ចដូចតទៅ÷

- ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដែលមានសកម្មភាព

ទ្រទ្រង់សេដ្ឋកិច្ចជនបទ

- ផ្តល់ឥណទានដល់ក្រុមហ៊ុន អង្គការកសិករឬសហគមន៍កសិកម្មដែលជានីតិបុគ្គល ដែលស្ថិតនៅក្នុងចង្វាក់អាជីវកម្ម និងផលិតកម្មពាក់ព័ន្ធនឹងវិស័យកសិកម្ម រួមមានជាអាទិ៍ ការផលិត ការស្តុកទុក ការកែច្នៃ ការចែកចាយ និងការនាំចេញនូវផលិតផលកសិកម្ម ជាពិសេសអង្ករ
- សហការនិង/ឬធ្វើសហជីវការ (Syndicate) ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងការផ្តល់ឥណទាន ដើម្បីអនុវត្តគម្រោងក្នុងវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងសេដ្ឋកិច្ចជនបទ
- អនុវត្តគម្រោងឥណទាន ឬគ្រប់គ្រងមូលនិធិផ្សេងទៀត ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍
- គ្រប់គ្រងកម្មវិធី ឬគម្រោងពិសេសណាមួយរបស់រាជរដ្ឋាភិបាល ឬគម្រោងពិសេសផ្សេងៗទៀតដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចរចាជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីទាក់ទាញហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានសម្រាប់ពង្រីកសកម្មភាពរបស់ **ធ.អ.ជ.**។

**មាត្រា៤.-**

**ធ.អ.ជ.** ត្រូវស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

**មាត្រា៥.-**

**ធ.អ.ជ.** មានប្រភពទុនមកពី÷

- ដើមទុនចុះបញ្ជីដំបូង និងដើមទុនផ្សេងទៀតដែលត្រូវបានបន្ថែមដោយរដ្ឋ
- ប្រាក់កម្ចី ឬប្រភពទុនស្របច្បាប់ផ្សេងទៀតដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦.-**

ទីស្នាក់ការកណ្តាលរបស់ **ធ.អ.ជ.** ស្ថិតនៅរាជធានីភ្នំពេញ និងអាចមានសាខាតាមការចាំបាច់។

## ជំពូកទី ២
## ការដឹកនាំនិងគ្រប់គ្រង

**មាត្រា៧.-**

**ធ.អ.ជ.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាពដូចតទៅ÷

១. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប ប្រធាន

២. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប សមាជិក

៣. អគ្គនាយក **ធ.អ.ជ.** សមាជិក

៤. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០១រូប សមាជិក

៥. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ០១រូប សមាជិក

៦. តំណាងបុគ្គលិករបស់ **ធ.អ.ជ.** ០១រូប សមាជិក

៧. តំណាងវិស័យឯកជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ០១រូប សមាជិក។

**មាត្រា៨.-**

**ធ.អ.ជ.** ត្រូវគ្រប់គ្រងដោយអគ្គនាយក ០១រូប ដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល លើកលែងតែតំណាងបុគ្គលិករបស់ **ធ.អ.ជ.** ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ឆ្នាំ។ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៩.-**

**ធ.អ.ជ.** ត្រូវបំពេញសកម្មភាព ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

**ធ.អ.ជ.** ត្រូវមានក្របខ័ណ្ឌអភិបាលកិច្ចសាជីវកម្មសមស្រប ដើម្បីធានាប្រសិទ្ធភាព សុខភាពហិរញ្ញវត្ថុ និងការរីកចម្រើនប្រកបដោយចីរភាព ដែលត្រូវចែងលម្អិតនៅក្នុងលក្ខន្តិកៈរបស់ **ធ.អ.ជ.**។

**មាត្រា១០.-**

**ធ.អ.ជ.** ត្រូវបន្តនិរន្តរភាពគតិយុត្ត រួមទាំងទ្រព្យគ្រប់ប្រភេទរបស់ខ្លួន តាមបទប្បញ្ញត្តិជាធរមាន គិតចាប់ពីពេលបង្កើតដោយអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យ ដូចខាងក្រោម÷

- អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ
- អនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

- អនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ